# របាយការណ៍ប្រចាំត្រីមាសទី១

## មករា-មីនា ឆ្នាំ២០១៤

### រៀបចំដោយ: លោកស្រី ប៊ុន រតនា

### ត្រួតពិនិត្យដោយ: លោក ផេង សៅឆេង និងលោកស្រី ម៉ប់ សូម៉ាយ៉ា

### មិថុនា ២០១៤

ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

## *MITH SAMLANH WOULD LIKE TO THANK ITS SPONSORS:*

- ***ACTED-PSF, AusAID/CDF, AusAID/HAARP, DAK Foundation, Dayer& Ahlstrom, Child Wise Cambodia, Deutsche Bank, Dan Church Aid/ChristianAid, European Union, EZECOM, Evert en Gisela Boudewijn Stichting, Inditex/Friends-Deutschland, Friends-International, Global Fund, Give2Asia, Juniclair,Kid's Colours ,La Chaine de L'Espoir, Planet Wheeler, Phnom Penh Capital Hall, Riverview Children Foundation, Secours Catholique/Reseaumondial Caritas, SNV Netherland Development Organization, Sipar/AFD, The Mercury Phoenix Trust, The Work Together Foundation (Smile Together Partnership), UNICEF, USAID, World Childhood Foundation and World Education.***

## អំពីអង្គការមិត្តសំឡាញ់

### ជីវប្រវត្ត

**អង្គការមិត្តសំឡាញ់** គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនាំមុខគេបង្កើតឡើងនៅខែសីហាឆ្នាំ១៩៩៤ ក្នុងកម្មវិធីការងារកុមារ/យុវវ័យបាត់បង់ឱកាស គ្រួសារ និងសហគមន៍របស់ពួកគេ។ អង្គការមិត្តសំឡាញ់ត្រូវបានចុះបញ្ជីជាអង្គការក្នុងស្រុកនៅក្រសួងមហាផ្ទៃ ចាប់តាំងពីឆ្នាំ២០០២។

ជារៀងរាល់ឆ្នាំ អង្គការមិត្តសំឡាញ់បានផ្តល់នូវកម្មវិធីផ្សេងៗ រួមមាន: ការបណ្តុះបណ្តាលវិជ្ជាជីវៈការអប់រំ ផ្តល់ការប្រឹក្សា អាហារ កន្លែងស្នាក់នៅ សេវាសុខាភិបាល និងការបង្កើតប្រាក់ចំណូលដល់កុមារ/យុវវ័យ ដែលបាត់បង់ឱកាសនិងក្រុមគ្រួសាររបស់ពួកគេចំនួន១៥,០០០នៅរាជធានីភ្នំពេញ។

### ទស្សនៈវិស័យ

យើងធ្វើការរួមគ្នា ដើម្បីការពារកុមារ/យុវវ័យដែលបាត់បង់ឱកាស និងក្រុមពាក់ព័ន្ធផ្សេងទៀត ហើយតាមរយៈការធ្វើការនេះយើងអាចបង្កើតឱកាសថ្មីៗដែលល្អសម្រាប់កសាងអនាគតពួកគេ។

### បេសកកម្ម

អង្គការមិត្តសំឡាញ់ គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបង្កើតឡើងដោយអង្គកាប្រ្រៀនអ៊ិនធើណេសិនណាល និងជាសមាជិកហ្វ្រេនអាល់ឡៃអ៊ិន ដែលធ្វើការជាមួយកុមារ/យុវវ័យដែលបាត់បង់ឱកាស គ្រួសារ និងសហគមន៍របស់ពួកគេក្នុងគោលបំណងកសាងសមត្ថភាពរបស់ពួកគេតាមរយៈ:

- **ការផ្តល់ការការពារ**កុមារ/យុវវ័យតាមផ្លូវជាមួយពីការរំលោភបំពានគ្រប់ទម្រង់ ដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។
- **ការធ្វើសមាហរណកម្ម**កុមារ/យុវវ័យតាមផ្លូវត្រឡប់ទៅរួមរស់ក្នុងសហគមន៍វិញដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិរបស់ពួកគេ។
- **ការទប់ស្កាត់**កុមារ/យុវវ័យតាមផ្លូវមិនឲ្យចូលរួមក្នុងសកម្មភាព និងស្ថានភាពប្រកបដោយគ្រោះថ្នាក់ដែលនាំឲ្យប៉ះពាល់ដល់អនាគតរបស់ពួកគេ។
- **ការកែលំអ**បែបបទការងាររបស់អង្គការតាមរយៈការជំរុញឲ្យមានការផ្តួចផ្តើមថ្មីៗដែលល្អដោយមានការចូលរួមយ៉ាងសកម្មពីកុមារ និងក្រុមយុវវ័យ។
- **ការកែប្រ**សង្គមគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដើម្បីជំរុញឲ្យមានបរិយាកាសអំណោយផល និងការប្រកាន់នូវឥរិយាបថថ្មីដែលល្អត្រឹមត្រូវ។

**គុណតម្លៃ:**

- ផ្តល់តម្លៃ និងផលប្រយោជន៍ប្រសើរដល់កុមារ
- តម្លាភាព
- និរន្តភាព
- ដំណោះស្រាយប្រកបដោយវិជ្ជមាន

**ទិដ្ឋភាពទូទៅ:**

អង្គការមិត្តសំឡាញ់បច្ចុប្បន្នអនុវត្តប្រាំពីរកម្មវិធីដ៏សំខាន់: ដូចជា ការការពារ/តាមផ្លូវ,ការពង្រឹងសិទ្ធិអំណាចយុវវ័យ,ការអប់រំ,ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ;សមាហរណកម្មគ្រួសារនិងការថែទាំជំនួស,បង្កើតប្រាក់ចំណូលគ្រួសារ,និងធុរៈកិច្ចសង្គម។ការងារនេះបានគាំទ្រដោយក្រុមឯកទេស៦នាក់ (អ្នកឯកទេសលើការការពារកុមារ,អ្នកឯកទេសវេជ្ជសាស្ត្រ,អ្នកឯកទេសគ្រប់គ្រងករណី,អ្នកឯកទេសគ្រឿងញៀន,អ្នកឯកទេសបំណិនជីវិត, អ្នកឯកទេសសុវត្ថិភាពកុមារ) និងក្រុមគ្រប់គ្រង,ក្រុមហិរញ្ញវត្ថុ,រដ្ឋបាល/ធនធានមនុស្ស/និងក្រុមតាមដាននិងវាយតម្លៃ។

# អក្សរកាត់

| | |
|---|---|
| ARV | ឱសថប្រឆាំងមេរោគអេដស៍ |
| DoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (មន្ទីរស.អ.យ) |
| CC | មណ្ឌលកែប្រែ |
| CCWC | គណៈកម្មាការឃុំសម្រាប់ស្ត្រី និងកុមារ |
| FSB | គម្រោងធុរៈកិច្ចសង្គម |
| FI | ហ្វ្រេនអុិនធើណេសិនណាល |
| HBP | សិប្បកម្មតាមផ្ទះ |
| HIV/AIDS | មេរោគអេដស៍/ជម្ងឺអេដស៍ |
| IEC | សម្ភារៈអប់រំ |
| ITP | ផែនការបណ្ដុះបណ្ដាលបុគ្គល |
| KPMG | ក្រុមហ៊ុន KPMG កម្ពុជា |
| MoU | អនុស្សារណៈយោគយល់គ្នា |

| | |
|---|---|
| MER | តាមដាន ត្រួតពិនិត្យ និងស្រាវជ្រាវ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនិង យុវនីតិសម្បទា (ក្រសួងស.អ.យ) |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MS | មិត្តសំឡាញ់ |
| NACD | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| NGO GPP | គម្រោងអភិបាលកិច្ច និងប្រតិបត្តិប្រកបដោយវិជ្ជាជីវៈរបស់អង្គការមិនមែន រដ្ឋាភិបាល |
| NFE | អប់រំក្រៅប្រព័ន្ធ |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៍ សើស្បែក និងកាមរោគ |
| PMTCT | សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន |
| STDs | ជំងឺកាមរោគ |
| SOP | បទដ្ឋាននៃនិតិវិធី |
| TH | មណ្ឌលស្នាក់នៅបណ្ដោះអសន្ន |
| VCCT | តេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ |

# សង្ខេបលទ្ធផលសម្រេចបាន

- កុមារ/យុវវ័យចំនួន៥,៩៤៧នាក់ (ស្រី ២,៣៣២នាក់) និងអាណាព្យាបាលចំនួន ២,៩៥៥ នាក់(១,៦៣០នាក់) បានទទួលសេវាកម្មនៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានាចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- អង្គការមិត្តសំឡាញ់បានផ្តល់សេវាកម្មចំនួន៣៩៨,៧៤៣(ស្រី១៣៩,៧៩២)ដល់កុមារ/យុវវ័យ និងអាណាព្យាបាលរបស់ពួកគេក្នុងត្រីមាសនេះ
- កុមារ/យុវវ័យចំនួន៩១នាក់(ស្រី ២៦នាក់)បានជួយគាំទ្រឲ្យចាកចេញពីជីវិតតាមផ្លូវចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- កុមារចំនួន១៤៤នាក់ (ស្រី ៦១នាក់)បានទទួលការអប់រំបំប៉នកំរិតបឋមសិក្សាចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- កុមារថ្មីចំនួន០១នាក់ បានជួយគាំទ្រ និងធ្វើសមាហរណកម្មទៅសាលារដ្ឋ ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- កុមារចំនួន ១,៣៨២នាក់ (ស្រី៥៩៧នាក់) បាននឹងកំពង់ជួយគាំទ្រឲ្យបន្តការសិក្សានៅសាលារដ្ឋ តាមរយៈការចុះសួរសុខទុក្ខនៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានាគាំទ្រឲ្យបន្តរៀននៅសាលារដ្ឋ ចាប់ពីថ្ងៃទី០១ មករា ឆ្នាំ២០១៤ និងកុមារចំនួន៤៦០នាក់ (ស្រី១៩៧នាក់) ឈប់ទទួលបានការគាំទ្រសម្ភារៈសិក្សា ដោយសារគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឲ្យរៀននៅសាលារដ្ឋ ។
- យុវវ័យចំនួន៣០៨នាក់ (ស្រី ៨៧នាក់)បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- យុវវ័យចំនួន ៣១នាក់ (ស្រី០៧នាក់) បានសមាហរណកម្មទៅកាន់ការងារ (ជួយស្វែងរកការងារធ្វើ បង្កើតអាជីវកម្មផ្ទាល់ខ្លួន ដាក់ការងារភ្លាមៗ និងស្វែងរកការងារដោយខ្លួនឯងនៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានាចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- កុមារ/យុវវ័យចំនួន២១៤នាក់(ស្រី៥៤នាក់)បានស្នាក់នៅមណ្ឌលបណ្តោះអាសន្នទាំង៣ប្រកបដោយសុវត្ថិភាព រួមមានអនាម័យ អាហារ ការព្យាបាល និងសម្ភារៈប្រើប្រាស់ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- កុមារ/យុវវ័យចំនួន៣៩នាក់(ស្រី ០៨នាក់) បានសមាហរណកម្មទៅកាន់គ្រួសារវិញ (គ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ គ្រួសារចិញ្ចឹម រស់នៅឯករាជ្យ និងរស់នៅជាក្រុម) នៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- អាណាព្យាបាល១៥៣នាក់ បានទទួលការគាំទ្រសកម្មភាពបង្កើតប្រាក់ចំណូល(អាជីវកម្មខ្នាតតូច សប្បុរកម្មតាមផ្ទះ)ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤
- សមាជិកបណ្តាញសុវត្ថិភាពកុមារចំនួន៧៣៦ នាក់(ស្រី ១៧១នាក់)រួមបញ្ចូលបណ្តាញសុវត្ថិភាពកុមារក្នុងសហគមន៍ចំនួន២២៨ នាក់(ស្រី ១៦៩នាក់)នៅរាជធានីភ្នំពេញ


ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| ហេតុផលនៃកិច្ចអន្តរាគមន៍ | សូចនាករដែល អាចផ្ទៀងផ្ទាត់បានយ៉ាងជាក់ស្តែង | លទ្ធផល |
| --- | --- | --- |
| **១.ការប្រតិបត្តិល្អ:**អង្គការមិត្តសំឡាញ់ត្រូវបានទទួលស្គាល់ជាកម្មវិធីប្រតិបត្តិល្អលំដាប់ថ្នាក់អន្តរជាតិ | | |
| ១.១ការគ្រប់គ្រងគឺជាការប្រតិបត្តិល្អហើយផ្តល់ការណែនាំជាយុទ្ធសាស្ត្រនិងការគាំទ្រប្រកបដោយប្រសិទ្ធិភាពដល់កម្មវិធី | **គណៈគ្រប់គ្រង:**<br>- កិច្ចព្រមព្រៀងគម្រោងការងារជាមួយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងត្រូវបានធ្វើ និងបន្តឲ្យទាន់ពេលវេលា<br>- ទំនាក់ទំនងរបស់អង្គការមិត្តសំឡាញ់ជាមួយម្ចាស់មូលនិធិនិងរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាពនិងតម្លាភាព<br>- ទំនាក់ទំនងជាមួយក្រុមប្រឹក្សាភិបាលប្រកបដោយប្រសិទ្ធិភាព<br>- បញ្ចប់លក្ខន្តិកៈថ្មីនិងបទបញ្ជាផ្ទៃក្នុងរបស់មិត្តសំឡាញ់សម្រាប់ក្រុមប្រឹក្សាភិបាលនិងជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលថ្មី<br>- រៀបចំឯកសារដើម្បីដាក់ពាក្យឡើងវិញសម្រាប់គម្រោងអភិបាលកិច្ចនិងប្រតិបត្តិប្រកបដោយវិជ្ជាជីវៈរបស់អង្គការមិនមែនរដ្ឋាភិបាល<br><br>**រចនាសម្ព័ន្ធ**<br>- រចនាសម្ព័ន្ធ របស់អង្គការមិត្តសំឡាញ់នឹង ធ្វើបច្ចុប្បន្នភាពដោយផ្អែកទៅលើតម្រូវការ ទាំងក្នុងនិងខាងក្រៅហើយការផ្លាស់ប្តូរនឹងធ្វើឲ្យមានប្រសិទ្ធិភាពនិងការឆ្លើយតប | **គណៈគ្រប់គ្រង:**<br>- មិត្តសំឡាញ់បានចុះហត្ថលេខាលើអនុស្សរណៈជាមួយក្រសួងអប់រំ យុវជននិងកីឡាដើម្បីបន្តការអនុវត្តរយៈពេល ៣ឆ្នាំបន្តទៀតនាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤។<br>- មិត្តសំឡាញ់នឹងចុះហត្ថលេខាលើអនុស្សរណៈជាមួយសាលារាជធានីភ្នំពេញនៅត្រីមាសបន្ទាប់។<br>- ក្នុងត្រីមាសនេះ ម្ចាស់មូលនិធិមួយចំនួនរួមមាន:Unicef, Wise, USAID (Ambassador), La Chaine de L’Espoir, Riverview and Planet Wheeler បានមកទស្សនៈកិច្ចនៅអង្គការមិត្តសំឡាញ់តាមរយៈប្រៀន្សអ៊ិនធើណេសិនណល។<br>- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនាខែមីនា ឆ្នាំ២០១៤ ដើម្បីអនុមត័លើលទ្ធផលសម្រេចបានឆ្នាំ២០១៣ ផែនការយុទ្ធសាស្ត្រ និងគំរោងថវិកាឆ្នាំ ២០១៤ ថែមទាំងបានពិភាក្សាលើការជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលចំនួន ០២ នាក់ទៀត។<br><br>**រចនាសម្ព័ន្ធ**<br>- បានរៀបចំរចនាសម្ព័ន្ធថ្មីសម្រាប់ក្រុមអណ្តូង និងច្បារអំពៅ ហើយកំពុងតែដំណើរការរៀបចំផែនទីសម្រាប់តំបន់កណ្តាលរាជធានីភ្នំពេញ |

<table>
<tr>
<td></td>
<td>- បន្ត និងធ្វើបច្ចុប្បភាពរចនាសម្ព័ន្ធក្រុមទាំងមូលនៅជាយក្រុង និងកណ្តាលរាជធានីភ្នំពេញ<br>- រៀបចំផែនការសម្រាប់កសាងអាគាររបស់អង្គការមិត្តសំឡាញ់<br><br>ការទំនាក់ទំនង/រ៉ៃអង្គ្រាសប្រាក់<br>- ការទំនាក់ទំនងខាងក្នុងនិងខាងក្រៅរបស់អង្គការមិត្តសំឡាញ់នឹងមានប្រសិទ្ធិភាពនិងធ្វើបច្ចុប្បន្នភាពឲ្យកាន់ប្រសើរឡើង<br>- អនុវត្តព្រឹត្តិការណ៍នៃការរ៉ៃអង្គ្រាសប្រាក់និងសម្ភារៈទំនាក់ទំនង រួមទាំងខួបលើកទី ២០ឆ្នាំនៃអង្គការមិត្តសំឡាញ់<br>- ធ្វើឲ្យមានសុវត្ថិភាពលើថវិកាម្ចាស់មូលនិធិ ដើម្បីធ្វើឲ្យស្ថានភាពនៃការផ្តល់ជំនួយមានភាពល្អប្រសើរ</td>
<td>ការទំនាក់ទំនង/រ៉ៃអង្គ្រាសប្រាក់<br>- សៀវភៅព័ត៌មានរបស់អង្គការមិត្តសំឡាញ់បានបកប្រែជាភាសាខ្មែរ។<br>- បានរៀបចំព្រឹត្តិការណ៍សប្បាយសប្បាយ សម្រាប់គ្រួសារ និងមិត្តភក្តិ ក្រោមចំណងជើង "ការញ៉ាំកម្សាន្តអមដោយ សម្លេង តន្ត្រីដ៏អស្ចារ្យ" ដើម្បីរ៉ៃអង្គាសថវិកានៅអង្គការមិត្តសំឡាញ់ នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០១៤។<br>- បានប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ និងខួបលើកទី ២០របស់អង្គការមិត្តសំឡាញ់។<br>- ធានាសុវត្ថិភាពលើការទទួលបានថវិកាពីម្ចាស់មូលនិធិEvert&GiselaនិងDFAT(ពីមុនជាAusAID) ព្រមទាំងម្ចាស់មូលនិធិថ្មី រួមមាន:Tesco និងComic Relief។</td>
</tr>
<tr>
<td colspan="3">២. រដ្ឋបាល&ធនធានមនុស្ស/ហិរញ្ញវត្ថុ និងការតាមដាន &វាយតម្លៃ:គឺជាការអនុវត្តន៍ដ៏ល្អបំផុតនិងផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធិភាពខ្ពស់ដល់កម្មវិធី</td>
</tr>
<tr>
<td>២.១<br>បទដ្ឋាននៃធនធានមនុស្ស<br>និងបទបញ្ជាផ្ទៃក្នុងមិត្ត</td>
<td>រដ្ឋបាលនិងធនធានមនុស្ស<br>- រៀបចំSoPsសម្រាប់ធនធានមនុស្សជាមួយប្រែ្យអ៊ិនធើណេសិនណល<br>- ធ្វើបច្ចុប្បន្នភាពបទបញ្ជាផ្ទៃក្នុងមិត្តសំឡាញ់ (អំពើពុក</td>
<td>រដ្ឋបាលនិងធនធានមនុស្ស<br>- បទបញ្ជាផ្ទៃក្នុងបានធ្វើបច្ចុប្បន្នភាព និងអនុវត្តដោយសហការជាមួយប្រែ្យអ៊ិនធើណេសិនណល។<br>- បុគ្គលិកចំនួន ២៨នាក់(ស្រី ០៦នាក់)បានជ្រើសរើសដោយផ្អែកលើគោលការណ៍</td>
</tr>
</table>



ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| | | |
|---|---|---|
| សំឡាញ់ នឹងត្រូវ អនុវត្ត | រលួយ/គ្រួសារ ជម្លោះផលប្រយោជន៍ កំរៃជើងសារ ។ល។) ស្របនឹងគោលនយោបាយហិរញ្ញវត្ថុថ្មី<br>- បណ្តុះបណ្តាល ណែនាំ និង ផែនការបណ្តុះបណ្តាលបុគ្គលទាំងអស់<br>- កសាងសមត្ថភាពអ្នកគ្រប់គ្រងថ្នាក់កណ្តាល អភិវឌ្ឍន៍អាជីព និងការលើកទឹកចិត្តបុគ្គលិកខាងក្នុងជាមួយក្រុមនីមួយៗ | នៃការជ្រើសរើសបុគ្គលិក ដើម្បីបំពេញកន្លែងទំនេរក្នុងមានបុគ្គលិកស្មគ្រ័ចិត្តចំនួន ០៣នាក់ (ស្រី០២នាក់) និងតំឡើងតួនាទីចំនួន០២នាក់(ស្រី០១នាក់) ព្រមទាំងបានផ្តល់ការណែនាំនិងតម្រង់ទិសដល់បុគ្គលិកចូលបំរើការងារក្នុងមាសនេះទៅលើ:<br>- បទបញ្ជាផ្ទៃក្នុង/នីតិវិធី និងរចនាសម្ព័ន្ធរបស់អង្គការមិត្តសំឡាញ់<br>- គោលការណ៍សមភាពយេនឌ័រ<br>- ក្រមសីលធម៌/គោលការណ៍ការពារកុមារ<br>- នីតិវិធីជំលោះផលប្រយោជន៍<br>- គោលការណ៍នៃការផ្តល់រង្វាន់ និងសំណូក<br>- កម្មវិធីមិត្តសំឡាញ់<br>- បុគ្គលិកចំនួន ១៣៨នាក់(ស្រី៨៧នាក់) ស្មើ១៩៦ដង បានទទួលការបណ្តុះបណ្តាលផ្សេងគ្នាទាំងនៅខាងក្នុង និងខាងក្រៅ រួមមាន: ភាសាអង់គ្លេស ការវាយតំលៃកម្មវិធីប្រកបដោយវិជ្ជាជីវៈ ការយល់ដឹងអំពីការលួចបន្លំ ឥទ្ធិពលដ៏មានអំណាចវិជ្ជមាន ការប្រមូលទិន្នន័យគ្រឿងញៀន ចិត្តសាស្រ្តសង្គម និងការតម្រង់ទិស រៀបចំដោយអង្គការមិត្តសំឡាញ់/ហ្វ្រេនអ៊ិនធើណេសិនណាល និងស្ថាបន័ខាងក្រៅផ្សេងទៀតដូចជា មជ្ឈមណ្ឌលអូស្រ្តាលីសំរាប់ការបណ្តុះបណ្តាល ស្ថានទូតអូស្រ្តាលី និងសកលវិទ្យាល័យខេមរៈ។<br>- ក្នុងត្រីមាសនេះ ប្រពន្ធ័គ្រប់គ្រងព័ត៌មានបានកត់ត្រាទិន្នន័យបុគ្គលិករួមមាន:<br>- បុគ្គលិកចំនួន ២៦៨នាក់(ស្រី១១១នាក់) ក្នុងនោះមានបុគ្គលិកស្ម័គ្រចិត្ត ០៣នាក់(ស្រី០២នាក់) និងបុគ្គលិកថ្មី២៨នាក់(ស្រី០៦នាក់)។ |

| | | |
|---|---|---|
| | | - បុគ្គលិកចំនួន ១១នាក់(ស្រី ០៣នាក់) បានបញ្ចប់កិច្ចសន្យាការងារ ក្នុងនោះមាន បុគ្គលិក ០៥នាក់លាឈប់ពីការងារ បុគ្គលិក០៥នាក់បានបញ្ចប់កិច្ចសន្យាការងារ និងបុគ្គលិក០១ នាក់បានបោះបង់ ។ |
| ២.២ បទដ្ឋាននៃហិរញ្ញវត្ថុ និងគោលនយោបាយនឹងត្រូវបានអនុវត្ត | ហិរញ្ញវត្ថុ:<br>- សៀវភៅណែនាំនីតិវិធី និងគោលនយោបាយរដ្ឋបាល និងហិរញ្ញវត្ថុ នឹងធ្វើបច្ចុប្បន្នភាពក្នុងករណីចាំបាច់<br>- បុគ្គលិកទាំងអស់នឹងទទួលបានគាំទ្រដោយយោងទៅតាមគោលការណ៍រដ្ឋបាល និងហិរញ្ញវត្ថុ និងនីតិវិធី<br>- សៀវភៅណែនាំសម្រាប់បុគ្គលិកដែលមិនមែនជាបុគ្គលិកហិរញ្ញវត្ថុដើម្បីគោរពគោលនយោបាយហិរញ្ញវត្ថុ<br>- របាយការណ៍ហិរញ្ញវត្ថុខាងក្នុង និងរបាយការណ៍ម្ចាស់មូលនិធិ នឹងត្រូវបានបញ្ចប់និងផ្ញើជូនក្រុមពាក់ព័ន្ធគណៈគ្រប់គ្រង/ម្ចាស់មូលនិធិទាន់ពេលវេលា<br>- រាល់របាយការណ៍អាជីវកម្មខាងក្នុងនឹងត្រូវបានបញ្ចប់និងផ្ញើរទាន់ពេលវេលា<br>- ការធ្វើសវនកម្មដោយអ្នកខាងក្រៅនឹងបង្ហាញពីប្រពន្ធ័ហិរញ្ញវត្ថុប្រកបដោយគុណភាព<br>- ការត្រួតពិនិត្យផ្នែកខាងក្នុងនឹងពង្រឹងលើការអនុវត្តន៍ទាំងមូលនៃអង្គការមិត្តសំឡាញ់<br>- បញ្ជីសារពើភណ្ឌនឹងត្រូវធ្វើបច្ចុប្បន្នភាព រាប់ និងត្រួតពិនិត្យដោយបុគ្គលិកគណនេយ្យរៀងរាល់ត្រីមាស និងឆមាស | ហិរញ្ញវត្ថុ:<br>- គោលការណ៍ហិរញ្ញវត្ថុ និងសៀវភៅណែនាំនីតិវិធីត្រូវបានពិនិត្យឡើងវិញដោយជំនួយការបច្ចេកទេសនៃអង្គការហ្វ្រេនឌ្សអ៊ិនធើណាសិនណល។<br>- រៀងរាល់ថ្ងៃទី១០នៃខែនីមួយៗ បុគ្គលិកហិរញ្ញវត្ថុបានផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែជូនគណៈគ្រប់គ្រង ក្រុមពាក់ពន្ធ័ ហើយរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ម្ចាស់មូលនិធិ ក៏បានរៀបចំ និងផ្ញើជូនទៅតាមកាលបរិច្ឆេទកំណត់នូវក្នុងកិច្ចព្រមព្រៀង។<br>- របាយការណ៍អាជីវកម្មក៏បានផ្ញើជូនក្រុមពាក់ពន្ធ័ទាំងអស់និងគណៈគ្រប់គ្រងរៀងរាល់ថ្ងៃទី១០នៃខែនីមួយៗ ។<br>- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៣ របាយការណ៍គម្រោងសហភាពអឺរ៉ុប និងDCA បានបញ្ចប់ធ្វើសវនកម្ម និងទទួលបានលទ្ធផលរបាយការណ៍ពីក្រុមហ៊ុនKPMG មុនថ្ងៃទី៣១ ខែមីនាឆ្នាំ២០១៤ ។<br>- របាយការណ៍សវនកម្មប្រចាំឆ្នាំរួមខាងក្រៅបានបញ្ចប់នាថ្ងៃទី៣១ខែមីនាឆ្នាំ ២០១៤ដោយក្រុមហ៊ុន KPMG ហើយសវនកម្មគម្រោងបានធ្វើផ្អែកទៅ |

| | | |
|---|---|---|
| | - ថវិកាប្រចាំឆ្នាំរបស់មិត្តសំឡាញ់ នឹងត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពទាន់ពេលវេលា<br>- របាយការណ៍ហិរញ្ញវត្ថុ នឹងធ្វើបទបង្ហាញដល់បុគ្គលិកទាំងអស់ ដោយបើកចំហរ និងប្រកបដោយតម្លាភាព រៀងរាល់កិច្ចប្រជុំប្រចាំត្រីមាស<br>- របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មប្រចាំឆ្នាំរបស់មិត្តសំឡាញ់នឹងដាក់ជាសាធារណៈនៅលើគេហទំព័ររបស់មិត្តសំឡាញ់<br>- បុគ្គលិកគណនេយ្យនឹងទទួលការបណ្តុះបណ្តាលនិងបន្តទទួលបានការគាំទ្របច្ចេកទេសពីប្រ៊ូនអ៊ិនធើណេសិនណល | តាមតម្រូវការរបស់ម្ចាស់មូលនិធិរួមមាន: និងDCA ។<br><br>- ក្រុមគណនេយ្យបានចុះត្រួតពិនិត្យសម្ភារៈនៅក្នុងឃ្លាំងរួមមានអង្ករ ទឹកដោះគោ សម្ភារៈកាត់បន្ថយភាពគ្រោះថ្នាក់ដោយគ្រឿងញៀន និងផលិតផលសិប្បកម្មតាមផ្ទះបន្ទាប់ពីត្រួតពិនិត្យរួចជាលទ្ធផលពុំមានភាពមិនប្រក្រតីកើតឡើងឡើយ ។<br>- ការលក់ដុំឥដ្ឋ និងប្រាក់សម្រាប់សិស្សបានត្រួតពិនិត្យដោយបុគ្គលិកគណនេយ្យរៀងរាល់ខែដើម្បីឲ្យមានតម្លាភាព និងគណនេយ្យភាព លើសពីនេះទៅទៀតក៏បានចុះត្រួតពិនិត្យមើលលើបណ្ណ័ចំណាយទាំងអស់ ដោយភាពជាក់លាក់ និងត្រឹមត្រូវផងដែរ។<br>- អចលនទ្រព្យទាំងអស់ ត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌ និងធ្វើបច្ចុប្បន្នភាពលើការបិទស្លាកសម្គាល់ជាប្រចាំ និងត្រួតពិនិត្យរៀងរាល់ខែ។<br>- បុគ្គលិកមិត្តសំឡាញ់បន្តទទួលការគាំទ្រផ្នែកហិរវត្ថុដោយប្រ៊ូនអ៊ិនធើណេសិនណល។ |
| **២.៣ មិត្តសំឡាញ់ធ្វើការតាមដាន និងវាយតម្លៃកម្មវិធីរបស់ខ្លួនយ៉ាងទៀតទាត់ ដើម្បីធានាថាកម្មវិធីគឺជាកម្មវិធីប្រតិបត្តិល្អប្រកបដោយប្រសិទ្ធិភាព** | **តាមដាន និងវាយតម្លៃ**<br>- កម្មវិធីត្រូវបានត្រួតពិនិត្យជាប្រចាំដើម្បីធានាលើការផ្តល់សេវាប្រកបដោយការអនុវត្តល្អ<br>- ឧបករណ៍ប្រមូលទិន្នន័យនិងសៀវភៅណែនាំនឹងធ្វើបច្ចុប្បន្នភាពយោងតាមរចនាសម្ព័ន្ធនិងសកម្មភាពថ្មី<br>- កសាងសមត្ថភាពប្រធានគម្រោងនិងអ្នកឯកទេស លើការត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការពង្រឹងសមត្ថភាពសម្រាប់ការវិភាគទិន្នន័យ | **តាមដាន និងវាយតម្លៃ**<br>- ក្រុមតាមដាន និងវាយតម្លៃ បានចុះប្រមូលទិន្ន័យនៅតាមតំបន់យ៉ាងទៀងទាត់សម្រាប់តាមដានក្រុមការងារ ដើម្បីធានាថាពួកគាត់បាន យល់ច្បាស់ពីទម្រង់នៃការប្រមូលទិន្នន័យនិងការរក្សាទុកទិន្នន័យប្រកបដោយសុវត្ថិភាព។<br>- ទម្រង់ការធ្វើផែនការ និងរបាយការណ៍ប្រចាំខែក្នុងតំបន់ អណ្តូង និងច្បារអំពៅ ត្រូវបានបង្កើតឡើង និងអនុវត្តទៅតាមរចនាសម្ព័ន្ធថ្មីរបស់អង្គការមិត្តសំឡាញ់។ |


ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| | | |
|---|---|---|
| | - អនុវត្តលើការវាយតម្លៃប្រចាំឆ្នាំនៃរបាយការណ៍ និងអនុសាសន៍គម្រោងដោយមានការជ្រើសរើស (អាជីវកម្មខ្នាតតូចការចូលរួម/មិត្តអប់រំមិត្ត សមាហរណកម្ម/គ្រួសារធម៌)<br>- ការវាយតម្លៃ អ្នកទទួលផល(មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន ផ្ទះបៃតង ក្លឹបប្រូហ្វេន្ស)<br>- ផ្ញើរបាយការណ៍ ជូនម្ចាស់មូលនិធិ និងស្ថាប័នរដ្ឋាភិបាលឲ្យបានទាន់ពេលវេលា<br>- ការស្រាវជ្រាវ និងវាយតម្លៃគម្រោងនឹងត្រូវធ្វើឡើងតាមតម្រូវការម្ចាស់មូលនិធិ | - បុគ្គលិកអង្គការមិត្តសំឡាញ់មកពីគម្រោងចំនួនចំនួន០៥ រួមមាន: មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន សមាហរណកម្ម ធុរៈកិច្ចសង្គមផ្ទះបៃតង និងអប់រំ បានទទួលការវគ្គរំលឹកឡើងវិញ ស្ដីពី ការប្រមូលទិន្នន័យប្រចាំថ្ងៃ និងប្រចាំខែ ។<br>- ការអង្កេតស្ដីពីការពារកុមារនៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្ន ការស្ទង់មតិគ្រឿងញៀនឆ្នាំ២០១៣ និងការស្ទង់មតិត្រួតពិនិត្យសមាជិកសុវត្ថិភាពកុមារប្រចាំត្រីមាសទី១ត្រូវបានធ្វើឡើងដោយ អ្នកឯកទេសអង្គការមិត្តសំឡាញ់ និងវិភាគដោយក្រុមតាមដាននិងវាយតម្លៃ លទ្ធផលនៃការស្ទង់មតិបាន ផ្ញើដល់ក្រុមពាក់ព័ន្ធសម្រាប់ពង្រឹងប្រសិទ្ធិភាពនៃគម្រោង។<br>- នៅត្រីមាសនេះ មិត្តសំឡាញ់ មិនត្រឹមតែបានផ្ញើរបាយការណ៍ជូនម្ចាស់មូលនិធិ រួមមាន:ACTED/PSF,DCA/CA, European Union, Friends-Deutschland,Give2Asia, Planet Wheeler, Smile Together Foundation , SIPAR/AFD, Riverview Foundation, USAID and World Childhood Foundationនិងថែមទាំងបានផ្ញើរបាយការណ៍ជូនស្ថាប័នរដ្ឋាភិបាលផ្សេងទៀត ដោយផ្អែកលើតម្រូវការរបស់ពួកគេ។<br>- បញ្ជីនៃការអង្កេតនិងវាយតម្លៃគម្រោងត្រូវបានចងក្រងនិងផ្ញើទៅជូនក្រុមពាក់ព័ន្ធទាំងអស់។ |
| **៣. ក្រុមការងារសេវាសង្គម:** នឹងផ្ដល់ការការពារដ៏ល្អប្រសើរការពង្រឹងសិទ្ធិអំណាច ការអប់រំ ការបណ្ដុះបណ្ដាល ការងារ និងសមាហរណកម្ម ដល់កុមារ/យុវវ័យ និងអាណាព្យាបាលចំនួន ១៥,០០០នាក់ ក្នុងមួយឆ្នាំ | | |
| **៣.១ កម្មវិធីតាមថ្នល់ដ៏ល្អត្រូវបានអនុវត្ត នៅ** | | **មណ្ឌលសំចត:**<br>ជាមណ្ឌលចំហដែលមានសុវត្ថិភាពដើម្បីផ្ដល់សេវាដល់ក្រុមគោលដៅដោយពុំមាន |

| | | |
|---|---|---|
| កណ្តាលរាជធានីភ្នំពេញ និងជាយក្រុង | **សរុបរួម:**<br>**<u>ការការពារ</u>**:តាមផ្ទះល់ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះល់នឹងផ្តល់សេវា ១,០០៥,០០០ ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៨,២០០នាក់ នៃក្រុមតាមផ្ទះល់<br>- អាណាព្យាបាលចំនួន ៤,៨០០នាក់ នៃក្រុមតាមផ្ទះល់<br>- បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១៥០នាក់និងយុវវ័យ២០នាក់សមាហរណកម្មទៅកាន់ការងារ<br>- បញ្ជូនទៅមជ្ឈមណ្ឌលអប់រំបានចំនួន ១០០នាក់<br>- បញ្ជូនទៅមជ្ឈមណ្ឌលបន្សាប(ផ្ទះបៃតង)ចំនួន ១៥០នាក់<br>- បុគ្គលចំនួន ៣៣០នាក់ នឹងទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ១៩០នាក់ នឹងបញ្ជូនមកពីមន្ទីរសង្គមកិច្ច | ការណាត់ជួប ការចុះឈ្មោះជាផ្លូវការឬការបញ្ជូន។ សេវាផ្តល់នៅមណ្ឌលសំចត និងនៅតាមផ្ទះល់រួមមាន: បំណិនជីវិត ការព្យាបាល ការអប់រំសក្រៅប្រព័ន្ធ សកម្មភាពកម្សាន្ត ។ល។<br>**ប្រធានបទបំណិនជីវិត:** (សុខភាពបន្តពូជ មេរោគអេដស៍/ជំងឺអេដស៍ កាមរោគ គ្រឿងញៀន អនាម័យ អាហារូបត្ថម្ភ ផែនការណ៍អនាគត ការអប់រំសុវត្ថិភាពតាមផ្ទះល់ ការថែទាំកុមារ សិទ្ធិកុមារ ចំណាកស្រុកមានសុវត្ថិភាព និងសារៈសំខាន់នៃការសិក្សា)។<br><br>**សរុបរួម:**<br>**<u>ការការពារ:</u>** តាមផ្ទះល់ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះល់បានផ្តល់សេវា ២៦៥,៩៧៤ដង(ស្រី ១០៣,៧៦៤)ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៥,៣១៣ នាក់(ស្រី ២,១៣២នាក់)នៃក្រុមតាមផ្ទះល់<br>- អាណាព្យាបាលចំនួន ២,៦៨៥នាក់(ស្រី ១,៩៦០នាក់)នៃក្រុមតាមផ្ទះល់<br>- បញ្ជូនយុវវ័យទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបានចំនួន ១៦នាក់(ស្រី ០៧នាក់) និងយុវវ័យចំនួន០២នាក់សមាហរណកម្មទៅកាន់ការងារ ។<br>- បញ្ជូនទៅមជ្ឈមណ្ឌលអប់រំបានចំនួន ៦៩នាក់(ស្រី ២៨នាក់)<br>- បញ្ជូនទៅមជ្ឈមណ្ឌលបន្សាប(ផ្ទះបៃតង)បានចំនួន ២៦នាក់(ស្រី ០២នាក់)<br>- បុគ្គលចំនួន ១២២នាក់(ស្រី ៥១នាក់)បានទទួលឯកសារស្របច្បាប់ (សំបុត្រកំណើតអត្តសញ្ញាណប័ណ្ណសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ៣១នាក់ ស្រី ០៩នាក់)បានបញ្ជូន មកពីមន្ទីរសង្គមកិច្ច |

| | | |
|---|---|---|
| | អង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ<br>- សមាជិកសុវត្ថិភាពកុមារនិងសុវត្ថិភាពកុមារសហគមន៍ចំនួន ៨០០នាក់ | អង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ។<br>- សមាជិកសុវត្ថិភាពកុមារចំនួន ៧៣៦នាក់ (ស្រី ១៧១នាក់)រួមចញ្ចូលសុវត្ថិភាពកុមារសហគមន៍២២៨នាក់(ស្រី១៦៩នាក់)<br><br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីភាពជាដៃគូអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការនៅក្នុងសង្កាត់ស្វាយប៉ាកនិងខ្ចួញនាថ្ងៃទី ១៧ខែមករាឆ្នាំ២០១៤។<br>- បានចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេស ស្តីពីសេវាគាំពារសង្គមនិងពលកម្មកុមារ នៅទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១១ខែកុម្ភៈឆ្នាំ ២០១៤។<br>- បានធ្វើការប៉ាន់ប្រមាណតំបន់និងក្រុមគោលដៅនៅរាជធានីភ្នំពេញដើម្បីធ្វើបច្ចុប្បន្នភាពផែនទីនិងការធ្វើការជាមួយក្រុមគោលដៅថ្មីជាពិសេសអ្នករកស៊ីផ្លូវភេទកម្មករសំណង់ អ្នកលាងឡាន កុមារបោះបង់ការសិក្សា និងយុវវ័យគ្មានការងារធ្វើ ។ល។<br>- បានចូលរួមកិច្ចប្រជុំជាមួយម្ចាស់មូលនិធិជាDCA/CAស្តីពីទម្រង់របាយការណ៍ប្រចាំឆ្នាំនៅភោជនីយដ្ឋានខ្មែរស៊ូរិន នាថ្ងៃទី០៤ខែមីនាឆ្នាំ ២០១៤។<br>- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងភាពជាដៃគូរវាងរដ្ឋបាលរាជធានីភ្នំពេញនិងសង្គមស៊ីវិលដើម្បីធ្វើការអភិវឌ្ឍសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញនៅសាលារាជធានីភ្នំពេញនាថ្ងៃទី១៨ខែមីនាឆ្នាំ ២០១៤។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីឪពុកម្តាយ នៅសណ្ឋាគារអ៊ីមភើរាហ្គាដិនវិឡានាថ្ងៃទី២១ខែមិនាឆ្នាំ២០១៤។ |
| | **តំបន់មាត់ទន្លេ** | **តំបន់មាត់ទន្លេ:** ក្រុមការងារតាមផ្លូវ និងមណ្ឌលសំចតមួយកំពុងដំណើរការដោយ |

| | | |
|---|---|---|
| | **ការការពារ:** តាមផ្ទះលំ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះលំនឹងផ្ដល់សេវា២០០,០០០ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,៥០០នាក់ នៃក្រុមតាមផ្ទះលំ<br>- អាណាព្យាបាលចំនួន៧៥០នាក់ នៃក្រុមតាមផ្ទះលំ<br>- បុគ្គលចំនួន ១៥០នាក់ នឹងទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ៧០នាក់ នឹងបញ្ជូនមកពីមន្ទីរសង្គមកិច្ចអង្គការ ដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ<br>- សមាជិកសុវត្ថិភាពកុមារនិងសុវត្ថិភាពកុមារសហគមន៍ចំនួន ៣០០នាក់ | បុគ្គលិកចំនួន០៩នាក់ (ស្រី០៥នាក់) មានទីតាំងស្ថិតនៅ ផ្ទះលេខ ៣៣Eo+E1ផ្លូវលេខ ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ។<br>**ការការពារ:** តាមផ្ទះលំ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះលំបានផ្ដល់សេវា ៤៨,១៥៩ ដង(ស្រី ២៦,៩៩២ដង) ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,១៥៦នាក់ (ស្រី ៥៣៦នាក់)នៃក្រុមតាមផ្ទះលំ<br>- អាណាព្យាបាលចំនួន៤៧៤នាក់ (ស្រី ២២៦នាក់) នៃក្រុមតាមផ្ទះលំ<br>- បុគ្គលចំនួន៧១នាក់(ស្រី៣៣នាក់) បានទទួលឯកសារស្របច្បាប់ (សំបុត្រកំណើតអត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)។<br>- កុមារ/យុវវ័យចំនួន ០៩នាក់(ស្រី០៣នាក់) បានបញ្ជូន មកពីមន្ទីរសង្គមកិច្ច អង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ។<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ២៩៦នាក់ (ស្រី៩៨នាក់) រួមបញ្ចូលសុវត្ថិភាព កុមារនៅសហគមន៍ចំនួន៥៧នាក់(ស្រី៤៧នាក់)។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- បានរៀបចំពិធីសូត្រមន្តសំរាប់បើកមណ្ឌលថ្មី ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៣៣Eo+E1ផ្លូវលេខ ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ នាថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤។ |
| | **តំបន់អូឡាំពិក:**<br>**ការការពារ:** តាមផ្ទះលំ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះលំនឹងផ្ដល់សេវា២០០,០០០ដល់ក្រុមគោលដៅ | - **តំបន់អូឡាំពិក:** ក្រុមការងារតាមផ្ទះលំ និងមណ្ឌលសំចតមួយ កំពុងដំណើរការដោយបុគ្គលិកចំនួន១២នាក់(ស្រី០៤នាក់)មានទីតាំងស្ថិតនៅក្នុងមណ្ឌលសំចតមាត់ទន្លេ ខណៈពេលក្រុមការងារកំពុងស្វែងរកមណ្ឌលសំចតថ្មី។ |

| | | |
|---|---|---|
| | - កុមារ/យុវវ័យចំនួន ១,៥00នាក់ នៃក្រុមតាមផ្ទះល់<br>- អាណាព្យាបាលចំនួន ៧00នាក់ នៃក្រុមតាមផ្ទះល់<br>- បុគ្គលចំនួន ១00នាក់ នឹងទទួលឯកសារស្របច្បាប់ (សំបុត្រកំណើត អត្តញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារនិងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ៦0នាក់ នឹងបញ្ជូនមកពីមន្ទីរសង្គមកិច្ចអង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ<br>- សមាជិកសុវត្ថិភាពកុមារនិងសុវត្ថិភាពកុមារសហគមន៍ចំនួន ២00នាក់ | **<u>ការការពារ:</u>** តាមផ្ទះល់ មណ្ឌលសំចតនិងសុវត្ថិភាពកុមារ<br>- ក្រុមតាមផ្ទះល់នឹងផ្តល់សេវា ៧០,៥៧២ដង (ស្រី២៦,១៩៨ដង) ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,០៤៣នាក់(ស្រី ៣៧៩នាក់) នៃក្រុមតាមផ្ទះល់<br>- អាណាព្យាបាលចំនួន ២៥៧នាក់(ស្រី ១៤៣នាក់) នៃក្រុមតាមផ្ទះល់<br>- បុគ្គលចំនួន ០៦នាក់ បានទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារនិងប័ណ្ណសមធម៌)។<br>- ក្មេងប្រុសចំនួន ០២នាក់ បានបញ្ជូនមកពីមន្ទីរសង្គមកិច្ច អង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ។<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ២០៤នាក់ (ស្រី ៣១នាក់) រួមបញ្ចូលសុវត្ថិភាពកុមារនៅសហគមន៍ចំនួន៥៧នាក់(ស្រី ៤៧នាក់)។<br><br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- ប្រធានក្រុមអូឡាំពិកបានចូលរួមកិច្ចប្រជុំស្តីពីភាពជាដៃគូកំពុងធ្វើការនៅក្នុងសហគមន៍ នៅការិយាល័យខណ្ឌ៧មករា នាថ្ងៃទី ២១ខែមករាឆ្នាំ ២០១៤។<br>- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៥៨ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី ១ស្តីពីរបាយការណ៍រីកចំរើនប្រចាំខែមិនានិងផែនការសម្រាប់ត្រីមាសបន្ទាប់ នៅសាលារាជធានីភ្នំពេញនាថ្ងៃទី ២១ខែមិនាឆ្នាំ២០១៤។ |
| | **សហគមន៍អណ្តូង:**<br>**សហគមន៍អណ្តូង** កំពុងផ្តល់សេវាតាមផ្ទះល់ ការការពារ ការពង្រឹងសិទ្ធិអំណាចយុវវ័យ ការអប់រំ និងការងារ។<br>**<u>ការការពារ:</u>**ការងារចុះសហគមន៍ និងមណ្ឌលសំចត | **សហគមន៍អណ្តូង:**<br>**សហគមន៍អណ្តូង**មានទីតាំងស្ថិតនៅសង្កាត់ ពោធិសែនជ័យ ដោយមានបុគ្គលិក ១៤នាក់(ស្រី ០៤នាក់) កំពុងផ្តល់សេវាការពារផ្សេងៗ រួមមាន: បំណិនជីវិត ការព្យាបាល ការអប់រំក្រៅប្រព័ន្ធ និងសកម្មភាពកម្សាន្ត។ |

| | | |
|---|---|---|
| | - ក្រុមតាមផ្ទះលប់នឹងផ្តល់សេវា ៥០,០០០ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,០០០នាក់ នៃក្រុមតាមផ្ទះលប់<br>- អាណាព្យាបាលចំនួន ១,០០០នាក់ នៃក្រុមតាមផ្ទះលប់<br>- បុគ្គលចំនួន ៣០នាក់ នឹងទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ១០នាក់ នឹងបញ្ជូនមកពីមន្ទីរសង្គមកិច្ចអង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្ត្រី និងកុមារ<br>- សមាជិកសុវត្ថិភាពកុមារនិងសុវត្ថិភាពកុមារសហគមន៍ចំនួន ១២០នាក់ | <u>**ការការពារ:**</u> សហគមន៍ តាមផ្ទះលប់ និងមណ្ឌលសំចត<br>- ក្រុមតាមផ្ទះលប់បានផ្តល់សេវា ១៦,៧៥៧ ដង(ស្រី ៧,៧០៨ដង)ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៩៤០នាក់(ស្រី ១៧៥នាក់)នៃក្រុមតាមផ្ទះលប់<br>- អាណាព្យាបាលចំនួន ២២៣នាក់(ស្រី ១៩០នាក់) នៃក្រុមតាមផ្ទះលប់<br>- បុគ្គលចំនួន ០៤ នាក់(ស្រី ០២នាក់) បានទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ១០៩នាក់(ស្រី ៥៥នាក់) រួមបញ្ចូលសុវត្ថិភាពកុមារនៅសហគមន៍ចំនួន៦៩នាក់(ស្រី ៥៥នាក់)។ |
| | **សហគមន៍ច្បារអំពៅ:**<br>កម្មវិធីសហគមន៍ច្បារអំពៅ កំពុងផ្តល់សេវាតាមផ្ទះលប់ ការការពារ ការពង្រឹងសិទ្ធិអំណាចយុវវ័យ ការអប់រំ និងការងារ។<br><br><u>**ការការពារ:**</u> សហគមន៍ តាមផ្ទះលប់ និងមណ្ឌលសំចត<br>- ក្រុមតាមផ្ទះលប់នឹងផ្តល់សេវា ១៥០,០០០ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ២,៥០០នាក់ នៃក្រុមតាមផ្ទះលប់<br>- អាណាព្យាបាលចំនួន ២,០០០នាក់ នៃក្រុមតាមផ្ទះលប់<br>- បុគ្គលចំនួន ៥០នាក់ នឹងទទួលឯកសារស្របច្បាប់ (សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ | **សហគមន៍ច្បារអំពៅ:**<br>កម្មវិធីសហគមន៍ច្បារអំពៅ មានទីតាំងស្ថិតនៅ ខណ្ឌមានជ័យ ដោយមានបុគ្គលិក ១៣នាក់(ស្រី ០៧នាក់) កំពុងផ្តល់សេវាការពារផ្សេងៗ រួមមាន: បំណិនជីវិត ការព្យាបាល ការអប់រំក្រៅប្រព័ន្ធ និងសកម្មភាពកម្សាន្ត។<br><u>**ការការពារ:**</u> សហគមន៍ តាមផ្ទះលប់ និងមណ្ឌលសំចត<br>- ក្រុមតាមផ្ទះលប់បានផ្តល់សេវា ៣៣,៣២៩ដង(ស្រី ១៩,៦១៦ដង)ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,៨៧៧នាក់(ស្រី ៨៣៥នាក់)នៃក្រុមតាមផ្ទះលប់<br>- អាណាព្យាបាលចំនួន១,៦២២ នាក់(ស្រី ៨៧១នាក់) នៃក្រុមតាមផ្ទះលប់<br>- បុគ្គលចំនួន ៣៦នាក់(ស្រី ១៦នាក់)បានទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)។ |

| | | |
|---|---|---|
| | និងប័ណ្ណសមធម៌)<br>- កុមារ/យុវវ័យចំនួន ៥០នាក់ នឹងបញ្ជូនមកពីមន្ទីរសង្គមកិច្ចអង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការ ឃុំសម្រាប់ស្រ្តី និងកុមារ<br>- សមាជិកសុវត្ថិភាពកុមារនិងសុវត្ថិភាពកុមារសហគមន៍ចំនួន ១៥០នាក់ | - កុមារ/យុវវ័យចំនួន ២០នាក់( ស្រី ០៦នាក់) បានបញ្ជូនមកពីមន្ទីរសង្គមកិច្ចអង្គការដៃគូ 3PCs Partner ប៉ូលីស និងគណៈកម្មាធិការឃុំសម្រាប់ស្រ្តី និងកុមារ។<br>- មានសមាជិកសុវត្ថិភាពកុមារសកម្មចំនួន ១៣២នាក់(ស្រី៣៩នាក់) រួមបញ្ចូលសុវត្ថិភាពកុមារនៅសហគមន៍ចំនួន៤០នាក់ (ស្រី៣៨នាក់)។ |
| | **មណ្ឌលគ្រឿងញៀនចល័ត**:កំពុងផ្តល់សេវាក្នុងតំបន់ទាំង៣ និងគោលដៅដទៃផ្សេងទៀត<br>- ក្រុមតាមផ្ទះលំនឹងផ្តល់សេវា១០០,០០០ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៧០០នាក់ នៃក្រុមតាមផ្ទះលំ<br>- កុមារ/យុវវ័យចំនួន ៥០នាក់ នឹងបញ្ជូនទៅមជ្ឈមណ្ឌលបន្សាប | **មណ្ឌលគ្រឿងញៀនចល័ត**:កំពុងផ្តល់សេវាក្នុងតំបន់ទាំង៣ និងគោលដៅដទៃផ្សេងទៀតជុំវិញរាជធានីភ្នំពេញ។<br>- ក្រុមតាមផ្ទះលំបានផ្តល់សេវា២៨,៧៨៥ដង(ស្រី១,៧៦០ដង)ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៣៨៥នាក់(ស្រី ៥៦នាក់)នៃក្រុមតាមផ្ទះលំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។<br>- កុមារ/យុវវ័យចំនួន១៧នាក់បានបញ្ជូនទៅមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។<br>- បុគ្គលចំនួន ០៥នាក់ បានទទួលឯកសារស្របច្បាប់(សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងប័ណ្ណសមធម៌)។ |
| | **មណ្ឌលយុវវ័យចល័ត**: ផ្តល់សេវាក្នុងតំបន់ទាំង៣ និងគោលដៅដទៃផ្សេងទៀត<br>- ក្រុមតាមផ្ទះលំនឹងផ្តល់សេវា១០០,០០០ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៨០០នាក់ នៃក្រុមតាមផ្ទះលំ<br>- អាណាព្យាបាលចំនួន៣៥០នាក់នឹងទទួលបានសេវាទាំងនោះ | **មណ្ឌលយុវវ័យចល័ត**: ផ្តល់សេវាក្នុងតំបន់ទាំង៣ និងគោលដៅដទៃផ្សេងទៀតជុំវិញរាជធានីភ្នំពេញ។<br>- ក្រុមតាមផ្ទះលំបានផ្តល់សេវា២៥,៦៤៧ដង(ស្រី៩,៧៣៥ដង)ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន៤១២នាក់( ស្រី១៥១នាក់) នៃក្រុមតាមផ្ទះលំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤<br>- អាណាព្យាបាលចំនួន១០៩នាក់(ស្រី ៨០នាក់ ) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ |



ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| | | |
|---|---|---|
| | | **ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- ក្នុងត្រីមាសនេះ បានរៀបចំព្រឹត្តិការណ៍ពិសេសនៅសហគមន៍ចំនួន ៣ដងដែលមានកុមារ/យុវវ័យ អ្នកជិតខាង និងអាជ្ញាធរមូលដ្ឋានបានចូលរួមចំនួន ៩៩៧ (ស្រី៩៦១នាក់)ក្រោមប្រធានបទ " យើងត្រូវចេះថែរក្សាសុខភាពខ្លួនឯង"អ្នកត្រូវតែការពារខ្លួនឯង"និង"សិទ្ធិស្មើគ្នា"។ |
| | **គម្រោងបង្វែរ**<br>- ប៉ុស្តិ៍ប៉ូលីសនៅរាជធានីភ្នំពេញចំនួន០៥នឹងធ្វើការសហការណ៍ជាមួយប្រព័ន្ធបង្វែរ<br>- នឹងទទួលកុមារ/យុវវ័យចំនួន ២០នាក់ពីប៉ូលីស និងអាជ្ញាធរតាមរយៈប្រព័ន្ធបង្វែរ | **គម្រោងបង្វែរ**<br>- ប៉ុស្តិ៍ប៉ូលីសនៅខណ្ឌចំនួន ០៥ បានទទួលព័ត៌មានស្តីពីគម្រោងបង្វែរ ហើយកំពុងរង់ចាំសេចក្តីសម្រេចលើកិច្ចសហការណ៍(ការចុះអនុសារណៈនៃការយោគយល់ជាមួយសាលារាជធានីភ្នំពេញ)។<br><br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- បុគ្គលិកមិត្តសំឡាញ់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីជម្លោះកុមារលើច្បាប់កុមារនិងគម្រោងបង្វែរជាមួយអង្គការជំនួយផ្លូវច្បាស់សំរាប់សហគមន៍(LAC)នាថ្ងៃទី២៨-២៩ខែមករាឆ្នាំ២០១៤។<br>- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីសេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជននៅក្រសួងសអ.យ នាថ្ងៃទី០៤ខែកុម្ភៈឆ្នាំ២០១៤។<br>- បានចែករំលែកព័ត៌មានស្តីពីការសាកល្បងគម្រោងបង្វែរជាមួយអង្គការលីកាដូ និងអង្គការផ្សេងទៀតដែលកំពុងធ្វើការលើបញ្ហាយុត្តិធម៌អនីតិជននិងផ្តល់ការគាំទ្រដល់ស្ត្រីនិងកុមារនៅក្នុងជម្លោះផ្លូវច្បាប់នាថ្ងៃទី០៦ខែមីនាឆ្នាំ ២០១៤។ |
| ៣.២ផ្តល់សិទ្ធិអំណាចដល់យុវវ័យនិងចូលរួម | **សរុបរួម**<br>មិត្តអប់រំមិត្តចំនួន៥៨៥នាក់ | **សរុបរួម**<br>មិត្តអប់រំមិត្តចំនួន៣២៧ (ស្រី១០៨នាក់) បានទទួលការបណ្តុះបណ្តាល និងចូល |

| | | |
|---|---|---|
| **យ៉ាងសកម្មនៅក្នុងសហគមន៍របស់ពួកគេ និងសង្គមជាតិ** | នឹងទទួលការបណ្តុះបណ្តាលនិងចូលរួមយ៉ាងសកម្ម មជ្ឈមណ្ឌលវិជ្ជាជីវៈ តំបន់មាត់ទន្លេ តំបន់អូឡាំពិក មណ្ឌលយុវវ័យចល័តទាំង២ និងសហគមន៍ (សហគមន៍អណ្តូង និងច្បារអំពៅ)<br>- សេវាចំនួន១៧៥,០០០ដែលផ្តល់ដោយមិត្តអប់រំមិត្ត<br>- ចំនួនសកម្មភាព និងព្រឹត្តិការណ៍ដឹកនាំដោយយុវវ័យ | រួមយ៉ាងសកម្ម (មជ្ឈមណ្ឌលវិជ្ជាជីវៈ តំបន់មាត់ទន្លេ តំបន់អូឡាំពិក មណ្ឌលយុវវ័យចល័តទាំង២និងសហគមន៍ (សហគមន៍អណ្តូងនិងច្បារអំពៅ)<br>- សេវាចំនួន៧,៨៨៣ដង(ស្រី ៣,៥២៣)ដែលបានផ្តល់ដោយមិត្តអប់រំមិត្ត<br>- កិច្ចប្រជុំយុវវ័យចំនួន ៨ដង បានធ្វើឡើងដោយបុគ្គលិកហ្វឹកហាត់ និងបានធ្វើសកម្មភាពកម្សាន្តសប្បាយ និងផ្តល់ការអប់រំបំណិនជីវិតចំនួន ១០៦ លើក ដល់យុវវ័យក្នុងត្រីមាសនេះ។ |
| | **ក្រុមតាមផ្ទះ តំបន់មាត់ទន្លេ អូឡាំពិក មណ្ឌលយុវវ័យចល័តទាំង២ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>**មិត្តអប់រំមិត្ត**<br>- មិត្តអប់រំមិត្តសកម្មចំនួន៤៦៨នាក់<br>- មិត្តអប់រំមិត្តនឹងផ្តល់សេវា១៣០,០០០ដងដល់ក្រុមគោលដៅ | **ក្រុមតាមផ្ទះ តំបន់មាត់ទន្លេ អូឡាំពិក មណ្ឌលយុវវ័យចល័តទាំង២ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>**មិត្តអប់រំមិត្ត**<br>- មានមិត្តអប់រំមិត្តសកម្មចំនួន២៥៤ នាក់(ស្រី ៨១៨នាក់)<br>- មិត្តអប់រំមិត្តបានផ្តល់សេវា៤,៤៨២ដង(ស្រី១,៨៨២) ដល់ក្រុមគោលដៅ |
| | **សហគមន៍អណ្តូង**<br><u>ការពង្រឹងសិទ្ធិអំណាចយុវវ័យ</u><br>**មណ្ឌលយុវវ័យខ្ញុំ និងអ្នក:**<br>- នឹងផ្តល់សេវាចំនួន៤០,០០០ដង ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៥០០នាក់<br>- អាណាព្យាបាលចំនួន៤០០នាក់<br><br>**មិត្តអប់រំមិត្ត**<br>- មិត្តអប់រំមិត្តសកម្មចំនួន៥៨នាក់ | **សហគមន៍អណ្តូង**<br><u>ការពង្រឹងសិទ្ធិអំណាចយុវវ័យ</u><br>**មណ្ឌលយុវវ័យខ្ញុំ និងអ្នក:**<br>- សេវាចំនួន១២,៩៤៣ដង(ស្រី ៦,៨៦០)បានផ្តល់ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ៣០៩នាក់(ស្រី ១០២នាក់)<br>- អាណាព្យាបាលចំនួន ២០១នាក់(ស្រី១១៥នាក់)<br><br>**មិត្តអប់រំមិត្ត**<br>- មិត្តអប់រំមិត្តសកម្មចំនួន៤៦នាក់(ស្រី ១២នាក់) |

| | | |
|---|---|---|
| | - មិត្តអប់រំមិត្តនឹងផ្តល់សេវាចំនួន១៥,០០០ដងដល់ក្រុមគោលដៅ<br>- ចំនួនសកម្មភាព និងព្រឹត្តិការណ៍ដឹកនាំដោយយុវវ័យ | - មិត្តអប់រំមិត្តបានផ្តល់សេវា ១,៤៣៩ ដង(ស្រី ៦៥៨)ដល់ក្រុមគោលដៅ<br>- កិច្ចប្រជុំយុវវ័យចំនួន ៦ដង បានធ្វើឡើងដោយបុគ្គលិកហ្វឹកហាត់ និងបានធ្វើសកម្មភាពកម្សាន្តសប្បាយ និងផ្តល់ការអប់រំបំណិនជីវិតចំនួន៥៣ លើកដល់យុវវ័យក្នុងត្រីមាសនេះ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- មិត្តអប់រំមិត្តចំនួន ០៥នាក់(ស្រី ០២នាក់) បានទស្សនៈកិច្ចសិក្សា ជាមួយ អង្គការដំណក់ទឹកនៅខេត្តព្រៃវែង នាថ្ងៃទី១៣ខែមិនាឆ្នាំ ២០១៤។<br>- កុមារ/យុវវ័យ អ្នកជិតខាង និងអាជ្ញាធរមូលដ្ឋានចំនួន១៦៧នាក់ (ស្រី៩៨នាក់) បានចូលរួមព្រឹត្តិការណ៍ពិសេសក្រោមប្រធានបទ " សិទ្ធិស្មើគ្នានៅ ក្រុមគ្រួសារ និងសង្គម"នៅមណ្ឌលយុវវ័យខ្ញុំ និងអ្នក នាថ្ងៃទី១៣ខែមីនាឆ្នាំ២០១៤។ |
| | **សហាគមន៍ច្បារអំពៅ**<br><u>ការពង្រឹងសិទ្ធិអំណាចយុវវ័យ</u><br>**មណ្ឌលយុវវ័យឆ្លាត**<br>- សេវាចំនួន១៦០,០០០នឹងផ្តល់ដល់ក្រុមគោលដៅ<br>- កុមារ/យុវវ័យចំនួន ១,០០០នាក់<br>- អាណាព្យាបាលចំនួន៥០០នាក់<br><br>**មិត្តអប់រំមិត្ត**<br>- មិត្តអប់រំមិត្តសកម្មចំនួន៥៩នាក់<br>- មិត្តអប់រំមិត្តនឹងផ្តល់សេវា៣០,០០០ដល់ក្រុមគោលដៅ | **សហាគមន៍ច្បារអំពៅ**<br><u>ការពង្រឹងសិទ្ធិអំណាចយុវវ័យ</u><br>**មណ្ឌលយុវវ័យឆ្លាត**<br>- សេវាចំនួន២៩,៧៨២ដង(ស្រី១០,៣៩៥ដង)បានផ្តល់ដល់ក្រុមគោលដៅ (សង្គ្រោះបឋមបំណិនជីវិត អប់រំក្រៅប្រព័ន្ធ និងសកម្មភាពកម្សាន្តសប្បាយ)<br>- កុមារ/យុវវ័យចំនួន ៨៦៨នាក់(ស្រី៤២៩នាក់)<br>- អាណាព្យាបាលចំនួន៧៦៧នាក់(ស្រី៤៩១នាក់)<br>**មិត្តអប់រំមិត្ត**<br>- មិត្តអប់រំមិត្តសកម្មចំនួន២៧នាក់(ស្រី១៤នាក់)<br>- មិត្តអប់រំមិត្តបានផ្តល់សេវា១,៩៦២ដង(ស្រី៨៨៣ដង)ដល់ក្រុមគោលដៅ |

| | | |
|---|---|---|
| | - ចំនួនសកម្មភាព និងព្រឹត្តិការណ៍ដឹកនាំដោយយុវវ័យ | - កិច្ចប្រជុំយុវវ័យចំនួន២ដង បានធ្វើឡើងដោយបុគ្គលិកហ្វឹកហាត់ និងបានធ្វើសកម្មភាពកម្សាន្តសប្បាយ និងផ្តល់ការអប់រំបំណិនជីវិតចំនួន៥៣ លើកដល់យុវវ័យក្នុងត្រីមាសនេះ។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- សហាគមន៍ច្បារអំពៅបានរៀបចំពិធីសូត្រមន្តបើកមណ្ឌលថ្មី ដែលលមានទីតាំងស្ថិតនៅផ្ទះលេខ ១៧៧ ផ្លូវលេខ ៣៧១ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ នាថ្ងៃទី ០២ ខែកុម្ភៈឆ្នាំ២០១៤ ។<br>- អ្នកចូលរួមចំនួន ៦២នាក់ (ស្រី ១៨នាក់) រួមមាន យុវវ័យ អាណាព្យាបាល និងអាជ្ញាធរមូលដ្ឋាន បានចូលរួមកិច្ចពិភាក្សាស្តីពីសុខភាពបន្តពូជ និងជំងឺកាមរោគ នៅមណ្ឌលយុវវ័យឆ្លាត នាថ្ងៃទី ២៣ ខែមីនាឆ្នាំ២០១៤។<br>- មិត្តអប់រំមិត្តចំនួន ២១នាក់(ស្រី ១៥នាក់) បានចូលរួមវគ្គរំលឹកស្តីពីសុខភាពបន្តពូជនៅមណ្ឌលយុវវ័យឆ្លាត នាថ្ងៃទី ២៨ ខែមីនាឆ្នាំ២០១៤។<br>- កុមារ/យុវវ័យ អាណាព្យាបាល អ្នកជិតខាង និងអាជ្ញាធរមូលដ្ឋានចំនួន១៥៨នាក់(ស្រី៩៥នាក់)បានចូលរួមព្រឹត្តិការណ៍ពិសេសក្រោមប្រធានបទ " យុវវ័យត្រូវតែមានចំណេះដឹងផ្នែកបំណិនជីវិត"នៅមណ្ឌលយុវវ័យឆ្លាត នាថ្ងៃទី១២ ខែកុម្ភៈឆ្នាំ២០១៤។ |
| ៣.៣ កុមារត្រូវបានគាំមាហារណកម្មទៅសាលារដ្ឋនិងបន្តការសិក្សានៅសាលារដ្ឋកាន់តែយូរកាន់តែល្អ | **កម្មវិធីអប់រំសុរបូម:**<br>- មិត្តសំឡាញ់កំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន២៨០មួយឆ្នាំ<br>- កុមារចំនួន២៥០នាក់ នឹងចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ | **កម្មវិធីអប់រំសុរបូម:**<br>- មិត្តសំឡាញ់បានផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន១៩៤នាក់(ស្រី ៦១នាក់) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤<br>- កុមារចំនួន១២៣នាក់(ស្រី៦៦នាក់)បានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ |

| | | |
|---|---|---|
| | - ត្រៀមរៀបចំធ្វើសមាហរណកម្មកុមារចំនួន ៥00នាក់ទៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន ១,000នាក់ នឹងបានចុះឈ្មោះចូលរៀនតាមរយៈយុទ្ធនាការចុះឈ្មោះចូលរៀន<br>- កុមារចំនួន ១,៥00នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- នឹងត្រៀមរៀបចំកិច្ចប្រជុំជាមួយមាតាបិតាចំនួន ៤លើក ដើម្បីត្រៀមធ្វើការសមាហរណកម្មទៅក្សាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន ១២0នាក់ នឹងធ្វើសមាហរណកម្មផ្ទាល់ទៅសាលារដ្ឋ (ក្រុមតាមផ្ទះល់)<br><br>**ការគាំទ្របច្ចេកទេស**<br>- សេវាការអប់រំក្រៅប្រពន្ធ័សរុបចំនួន ៩0,000 នឹងផ្តល់ដល់កុមារ/យុវវ័យ នៅតាមផ្ទះល់ មណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- បុគ្គលិកចំនួន៦0នាក់ នឹងទទួលបានការបណ្តុះបណ្តាលស្តីពីសកម្មភាពអប់រំក្រៅប្រព័ន្ធ<br>- សម្ភារៈអប់រំក្រៅប្រព័ន្ធថ្មី នឹងត្រូវបង្កើតនិងធ្វើបច្ចុប្បន្នភាព<br>- សៀវភៅណែនាំ ស្តីពីការអប់រំក្រៅប្រព័ន្ធ នៅតាមផ្ទះល់ ក្នុងមណ្ឌល និងសមាហរណកម្មទៅសាលារដ្ឋ នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់ | - បានធ្វើសមាហរណកម្មកុមារចំនួន 0១នាក់ទៅសាលារដ្ឋចាប់ពីថ្ងៃទី 0១ ខែមករា ឆ្នាំ ២0១៤<br>- យុទ្ធនាការចុះឈ្មោះចូលរៀននឹងប្រព្រឹត្តទៅក្នុងត្រីមាសទី ៣<br>- កុមារចំនួន ១,៣៨២នាក់ (ស្រី ៥៩៧នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋ និងកុមារចំនួន៩៦0នាក់ (ស្រី ១៩៧នាក់) ឈប់ទទួលបានការគាំទ្រសម្ភារៈសិក្សា ដោយសារគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឲ្យរៀននៅសាលារដ្ឋ ។<br>- បានរៀបចំកិច្ចប្រជុំមាតាបិតាសិស្សដែលមានអ្នកចំនួន១៦0នាក់(ស្រី ១២៨នាក់) ដើម្បី ជ្រើសរើសតំណាងមាតាបិតាសម្រាប់ឆ្នាំ ២0១៤ នៅក្លឹមប្រៀន្ស នាថ្ងៃទី ១៨ ខែមករា ឆ្នាំ២0១៤ ជាលទ្ធផលមានមាតាបិតាគសិស្សចំនួន៣១នាក់ (ស្រី ២៧នាក់)ត្រូវបានជ្រើសរើសជាតំណាងក្នុងឆ្នាំ ២0១៤នេះ។<br><br>**ការគាំទ្របច្ចេកទេស**<br>- សេវាការអប់រំក្រៅប្រពន្ធ័សរុបចំនួន ៣៤,៣៦១ដង(ស្រី ១៣,00៣)បានផ្តល់ដល់កុមារ /យុវវ័យ នៅតាមផ្ទះល់ មណ្ឌលអប់រំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ១៥នាក់(ស្រី 0៦នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពីសកម្មភាពអប់រំក្រៅប្រព័ន្ធនៅតាមផ្ទះល់ និងមជ្ឈមណ្ឌលអប់រំ ។<br>- បានចុះមូលដ្ឋានចំនួន ៥៩ដង នៅ៤ តំបន់នៃក្រុមតាមផ្ទះល់ មជ្ឈមណ្ឌលអប់រំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និង សាលារដ្ឋ ដើម្បីពង្រឹងលើវិធីសាស្រ្តក្នុងការបង្រៀននិងបង្កើតសម្ភារៈបង្រៀន។ |



ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| | | |
|---|---|---|
| | - ការវាយតម្លៃលើសកម្មភាពអប់រំក្រៅប្រព័ន្ធ<br><br>**ដៃគូ**<br>- នឹងបង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសាលារដ្ឋរៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមការងារទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៣០នាក់ នឹងត្រូវបានស្វែងរក និងទទួលការបណ្តុះបណ្តាល<br>- ដៃគូសាលារដ្ឋនឹងទទួលការបណ្តុះបណ្តាល និងការគាំទ្រក្នុងការប្រើប្រាស់ឧបករណ៍សិក្សា | - ល្បែងកម្សាន្តនៃឧបករណ៍សិក្សាថ្មីចំនួន ០៣ បានបង្កើតរួមមាន: ល្បែងផ្គុំរូប ល្បែងចងចាំ និងល្បែងបង្កើនពាក្យ។<br><br>**ដៃគូ**<br>- បានចងក្រងបញ្ជីឈ្មោះសាលារដ្ឋ ដើម្បីមានភាពងាយស្រួលសម្រាប់ការទំនាក់ទំនង និងតាមដានសាសារដ្ឋ ។<br>- បានធ្វើការតាមដានសាលារដ្ឋចំនួន៥លើការប្រើប្រាស់ឧបករណ៍សិក្សា។ |
| | **មជ្ឈមណ្ឌលអប់រំ:**<br><br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន២០០នាក់ក្នុងមួយឆ្នាំ<br>- ត្រៀមរៀបចំធ្វើសមាហរណកម្មកុមារចំនួន ១៥០នាក់ទៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន ១,៣០០នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន៥០នាក់ នឹងបានចូលរៀនថ្នាក់បំប៉នបន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- សេវានៃការតាមដានកុមាររៀននៅសាលារដ្ឋចំនួន២៥,០០០ដង | **មជ្ឈមណ្ឌលអប់រំ:**<br>**មជ្ឈមណ្ឌលអប់រំ**ផ្តល់សកម្មអប់រំបំប៉នកំរិតបឋមសិក្សាដើម្បីសម្របសម្រួល លើការសមាហរណកម្មសិស្សទៅសាលារដ្ឋ និងផ្តល់ការអប់រំជាមូលដ្ឋានដល់កុមារដែលរស់នៅនិងធ្វើការតាមថ្នល់/សហគមន៍ ។<br><br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន១៣០នាក់(ស្រី ៥៥នាក់)ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤<br>- ការធ្វើសមាហរណកម្មកុមារទៅសាលារដ្ឋនឹងធ្វើនៅចុងត្រីមាសទី ៣។<br>- កុមារចំនួន ៩១១ នាក់(ស្រី៤២៧នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សា នៅសាលារដ្ឋ និងកុមារចំនួន៣២៣ នាក់(ស្រី១៣៥នាក់) ឈប់ទទួលបានការគាំទ្រសម្ភារៈសិក្សា ដោយសារគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឲ្យរៀននៅសាលារដ្ឋ ។<br>- កុមារចំនួន៣២ នាក់(ស្រី១៥នាក់) បានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅ |

<table>
<tr>
<td></td>
<td></td>
<td>សាលារដ្ឋចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤<br>- សេវានៃការតាមដានសិស្សនៅសាលារដ្ឋចំនួន២,៥១០ ដង(ស្រី១,១៥៩) បានធ្វើឡើងជាមួយសិស្សកំពុងរៀននៅសាលារដ្ឋ។<br><br>ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:<br>- ប្រធានមជ្ឈមណ្ឌលអប់រំ បានចូលរួមកិច្ចប្រជុំស្តីពីអប់រំសំរាប់ទាំងអស់នៅភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល នាថ្ងៃទី២០ខែកុម្ភៈឆ្នាំ២០១៤។</td>
</tr>
<tr>
<td></td>
<td>សហគមន៍អណ្តូង<br>អប់រំក្រៅប្រព័ន្ធ<br><br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន៣០នាក់ ក្នុងមួយឆ្នាំ<br>- យុវវ័យចំនួន០៥នាក់ចូលរៀនថ្នាក់អក្ខរកម្ម<br>- អាណាព្យាបាលចំនួន៣០នាក់ចូលរៀនថ្នាក់អក្ខរកម្ម<br><br>ថ្នាក់បំប៉ន<br>- កុមារចំនួន១០០នាក់ នឹងបានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ<br><br>សមាហរណកម្មទៅសាលារដ្ឋ<br>- សមាហរណកម្មកុមារថ្មីចំនួន៥០នាក់ទៅសាលារដ្ឋ<br>- កុមារចំនួន២០០នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ</td>
<td>សហគមន៍អណ្តូង<br>អប់រំក្រៅប្រព័ន្ធ<br><br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន០៣(ស្រី០នាក់)ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។<br>- អាណាព្យាបាលចំនួន១៦នាក់(ស្រី១២នាក់)ចូលរៀនថ្នាក់អក្ខរកម្មចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។<br>ថ្នាក់បំប៉ន<br>- កុមារចំនួន ៧៣នាក់(ស្រី៣៨នាក់)បានចូលរៀនថ្នាក់បំប៉នបន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។<br><br>សមាហរណកម្មទៅសាលារដ្ឋ<br>- កុមារចំនួន ១៥៥នាក់ (ស្រី៨០នាក់) បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋនិងកុមារចំនួន៣០នាក់ (ស្រី១២នាក់) ឈប់ទទួលបានការគាំទ្រសម្ភារៈសិក្សា ដោយសារគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឲ្យរៀននៅសា</td>
</tr>
</table>



ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ / ៤២៦ ៧៤៨ អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

| | | |
|---|---|---|
| | - កុមារចំនួន ៤០០នាក់ នឹងបានចុះឈ្មោះចូលរៀនតាមរយៈយុទ្ធនាការចុះឈ្មោះចូលរៀន | លារដ្ឋ ។ |
| | **សហគមន៍ច្បាអំពៅ**<br>**អប់រំក្រៅប្រព័ន្ធ**<br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន៥០នាក់ ក្នុងមួយឆ្នាំ<br>- យុវវ័យចំនួន១៥នាក់នឹងបានចូលរៀនថ្នាក់អក្ខរកម្ម<br>- អាណាព្យាបាលចំនួន ១៥នាក់នឹងបានចូលរៀន ថ្នាក់អក្ខរកម្ម<br><br>**ថ្នាក់បំប៉ន**<br>- កុមារចំនួន១០០នាក់ នឹងបានចូលរៀនថ្នាក់បំប៉ន បន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋក្នុងមួយឆ្នាំ<br><br>**សមាហរណកម្មទៅសាលារដ្ឋ**<br>- សមាហរណកម្មកុមារថ្មីចំនួន១០០នាក់ទៅសាលារដ្ឋ<br>- កុមារចំនួន២៥០នាក់ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងមួយឆ្នាំ<br>- កុមារចំនួន៤០០នាក់ នឹងបានចុះឈ្មោះចូលរៀនតាមរយៈយុទ្ធនាការចុះឈ្មោះចូលរៀន | **សហគមន៍ច្បាអំពៅ**<br>**អប់រំក្រៅប្រព័ន្ធ**<br>- មជ្ឈមណ្ឌលអប់រំកំពុងផ្តល់ការអប់រំបំប៉នកំរិតបឋមសិក្សាដល់កុមារចំនួន ១១នាក់(ស្រី០៦នាក់)ចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤<br>- យុវវ័យចំនួន០៣នាក់(ស្រី០នាក់)បានចូលរៀនថ្នាក់អក្ខរកម្មចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤<br><br>**ថ្នាក់បំប៉ន**<br>- កុមារចំនួន១៨នាក់(ស្រី១៣នាក់)បានចូលរៀនថ្នាក់បំប៉នបន្ទាប់ពីការបញ្ជូនទៅសាលារដ្ឋចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។<br><br>**សមាហរណកម្មទៅសាលារដ្ឋ**<br>- កុមារចំនួន ១១៧នាក់(ស្រី៤៨នាក់) បានទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋនិងកុមារចំនួន ៣៦នាក់ (ស្រី១៦នាក់) ឈប់ទទួលបានការគាំទ្រសម្ភារៈសិក្សា ដោយសារគ្រួសាររបស់ពួកគេអាចមានលទ្ធភាពក្នុងការគាំទ្រឲ្យរៀននៅសាលារដ្ឋ ។ |
| | **ក្លឹបប្រហ្វេន្ស:**កំពុងផ្តល់សេវាសកម្មភាពខាងក្នុង និងខាងក្រៅចំនួន ១០០,០០០ រួមមាន បណ្ណាល័យ រាំ កីឡា ល្បែង គំនូរ ទស្សនកិច្ចសិក្សា និងព្រឹត្តិការណ៍ពិសេស ដល់កុមារទាំងអស់នៅមជ្ឈ | **ក្លឹបប្រហ្វេន្ស:** ជាមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់ ដែលកុមារ/យុវវ័យអាចអនុវត្តសកម្មភាពកម្សាន្តសប្បាយ និងវប្បធម៌រួមមាន: កីឡា គំនូរ ផាត់ពណ៌ បណ្ណាល័យរាំ និងតន្ត្រី។ |

| | | |
|---|---|---|
| | មណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងកុមារមកពីតាមថ្នល់ក្នុងមួយឆ្នាំ<br>- ក្លឹបប្រៀនុនឹងបើកសម្រាប់កុមារ/យុវវ័យនៅតាមថ្នល់ និង សហគមន៍ចំនួន២ដងក្នុងមួយសប្តាហ៍ ដើម្បីផ្តល់សេវាបំណិនជីវិតចំនួន២០,០០០ដងដល់ពួកគេ | - បានផ្តល់សេវាសកម្មភាពខាងក្នុង និងខាងក្រៅ ចំនួន ៣៩,៣៧៣ដង (ស្រី១២,៥៥៨ដង) រួមមាន បណ្ណាល័យ រាំ កីឡា ល្ខោន គំនូរ ទស្សនកិច្ចសិក្សា និង ព្រឹត្តិការណ៍ពិសេស ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងកុមារមកពីតាមថ្នល់ក្នុងត្រីមាសនេះ<br>- ក្លឹបប្រៀនុ បើកសម្រាប់កុមារ/យុវវ័យនៅតាមថ្នល់ និងសហគមន៍ចំនួន ២ដងក្នុងមួយសប្តាហ៍ដើម្បីផ្តល់សេវាបំណិនជីវិតចំនួន៦,៩៨៥ដង (ស្រី ១,៨៨៧)។<br>**ព្រឹត្តិការណ៍ និងកំណត់សម្គាល់ពិសេស:**<br>- សេវាចំនួន៣៨១ដង (ស្រី ២៤៧)ដង នៃកុមារ/យុវវ័យបានចូលរួមការប្រកួតកីឡានៅខាងក្រៅរួមមាន: ដើរប្រណាំង លោត រត់ ចោលជុំដែកបាល់បោះ និងវាយប៉េងប៉ុង។<br>- កុមារ/យុវវ័យចំនួន ៥៨ នាក់(ស្រី២៧នាក់) បានចូលរួមសម្តែងប្រចាំត្រីមាសក្រោមប្រធានបទ ខួបទី២០ ឆ្នាំនៃអង្គការមិត្តសំឡាញ់ ដែលមានអ្នកទស្សនាចូលរួមចំនួន ៨៣០នាក់នៅក្លឹបប្រៀនុ នាថ្ងៃទី ២៧ ខែមីនាឆ្នាំ២០១៤។<br>- កុមារ/យុវវ័យចំនួន១៨០ នាក់(ស្រី ៧៦នាក់) បានចូលរួមបង្កើតទីក្រុងរបស់ពួកគេ ដែលជាផ្នែកនៃពិធីទីក្រុងយើង នៅមិត្តសំឡាញ់ នាថ្ងៃទី ២១ខែមករាឆ្នាំ២០១៤។<br>- កុមារ/យុវវ័យចំនួន៣០នាក់ (ស្រី ១៨នាក់) បានចូលរួមសិក្ខាសាលាស្តីពីសិល្បៈ និងតន្ត្រី ជាមួយក្រុមBloco Malagasy នៅមិត្តសំឡាញ់ នាថ្ងៃទី ១១ខែមីនាឆ្នាំ ២០១៤។<br>- បានដឹកនាំកុមារ/យុវវ័យចំនួន៤៥នាក់ (ស្រី ១៩នាក់) បានចូលរួមទស្សនាព្រះបរមរាជវាំង នាថ្ងៃទី១៧ខែមករា និងថ្ងៃទី២១ខែមិនាឆ្នាំ ២០១៤។<br>- សេវាចំនួន៦៩៨ដង (ស្រី ២៦៣ដង) នៃកុមារ/យុវវ័យបានចូលរួមគូររូបនៅរបងទ្វារ |

| | | |
|---|---|---|
| | | ខាងមុខអង្គការមិត្តសំឡាញ់។ |
